- សងខាងកំណាត់ផ្លូវទៅសាលាស្រុក ចាប់ពីសាលាស្រុក ដល់ផ្លូវជាតិលេខ៣ (លើកលែងកំណាត់ផ្លូវដែលមានចែងក្នុងប្រភេទមួយ)

<u>**ប្រភេទទីបួន**</u> ÷ ដីក្រៅពីការកំណត់ក្នុងប្រភេទខាងលើ (ដីលំនៅដ្ឋាន/ ដីស្រែ-ចំការ)

១- ឃុំស្វាយរំពារ មាន ១៤ភូមិ គឺ ÷

ក. ភូមិធ្លក ភូមិខ្នាតានង់ ភូមិស្រែព្រីង និងភូមិផ្សារស្លាបលែង

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិកណ្តៀង ភូមិត្រពាំងស្បា ភូមិស្លែង ភូមិស្លាប់លែង ភូមិកៀ្ឿរ ភូមិត្រាំសសរ ភូមិព្រៃដុប ភូមិត្រើល ភូមិទួល និងភូមិអូរព្រាល

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

២- ឃុំកក់ មាន ១៤ភូមិ គឺ ÷

ក. ភូមិតារាជ

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិទ័ពម្រាក់ ភូមិក្រាំងគ្រោក ភូមិពេជ្រ ភូមិត្រពាំងទាប ភូមិថ្មីក ភូមិជើងភ្នំ ភូមិត្រពាំងឈូក ភូមិក្បាលថ្នល់ ភូមិត្រពាំងព្រីង ភូមិខ្លា ភូមិឫស្សីវាល ភូមិព្រៃឈ្នួល និងភូមិត្រពាំងករសាំង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- ឃុំព្រះខែ មាន ០៩ភូមិ គឺ ÷

ក. ភូមិបឹង

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិត្រពាំងប្រិយ៍ ភូមិឃ្លោក ភូមិថ្នល់ដាច់ ភូមិថ្នល់ ភូមិខ្នងភូមិ ភូមិត្រពាំងវែង ភូមិព្រៃបាក្រុង និងភូមិត្នោតម្ទើម

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៤- ឃុំស្វាយចចិប មាន ១៥ភូមិ គឺ ÷

ក. ភូមិឫស្សីយុល ភូមិស្លុក និងភូមិពពូល

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិចារ្យ ភូមិត្រពាំងខ្ទុំ ភូមិអណ្តូងល្ហា ភូមិអន្លង់លាក់ ភូមិចេក ភូមិចចិប ភូមិសង្កែលាក់ ភូមិត្រយឹងទេ ភូមិពង្រ ភូមិជ្រៃ ភូមិខ្នាចកន្ទួត និងភូមិត្រពាំងថ្លុក

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំនិទាន មាន ១៥ភូមិ គឺ ÷

ក. ភូមិត្រពាំងទូក និងភូមិនរាយណ៍

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិត្រពាំងខ្យង ភូមិត្រពាំងអណ្តូង ភូមិត្រពាំងសាលា ភូមិត្រពាំងរំដេញ ភូមិក្រសាំងគាគង់ ភូមិត្រពាំងខ្នារ ភូមិសេរីអណ្តែត ភូមិត្រពាំងស្តៅ ភូមិត្រពាំងឈ្លូក ភូមិត្រាំកង់ ភូមិពោធិត្បែង ភូមិដីក្រហម និងភូមិហង្ស

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៦- ឃុំពោធិព្រាល មាន ១៨ភូមិ គឺ ÷

ក. ភូមិត្រពាំងខ្នារ ភូមិតាងួន ភូមិព្រៃត្បែង និងភូមិពោធិ

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិអន្លង់ដែកកណ្តាល ភូមិស្រែខ្មែរ ភូមិចំបក់រន្ធខាងត្បូង ភូមិចំបក់រន្ធខាងជើង ភូមិម្រាលត្នោតជើង ភូមិសាឡី ភូមិក្រាបធំ ភូមិម្រាលត្នោតត្បូង ភូមិអូរចារ្យ ភូមិថ្មី ភូមិចំរើនផល ភូមិតាដែងថ្មី ភូមិតាដែងចាស់ និងភូមិព្រៃល្មេ

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៧- ឃុំបសេដ្ឋ មាន ២២ភូមិ គឺ ÷

ក. ភូមិក្រុមហ៊ុន ភូមិកន្លង់ និងភូមិស្រែព្រោក

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិព្រៃរំដួលត្បូង ភូមិចំការទួល ភូមិព្រៃរំដួលជើង ភូមិទួលខ្វាយ ភូមិបឹងធ្នង់ ភូមិព្រៃរំដួលកើត ភូមិតាញៀង ភូមិព្រៃរំដួលលិច ភូមិខ្លុបវែង ភូមិត្រពាំងផុង ភូមិចាស់ ភូមិសំពរ ភូមិបឹងស្លុក ភូមិត្រពាំងឈូក ភូមិព្រៃម៉ើ ភូមិព្រៃគោកត្រប់ ភូមិព្រៃឈើទាល ភូមិបឹងសង្កែ និងភូមិត្នោតពេង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៨- ឃុំពោធិចំរើន មាន ១៤ភូមិ គឺ ÷

ក. ភូមិព្រៃត្បែង ភូមិសក្ការៈ ភូមិឱ្ទបុន និងភូមិភ្នំតូច

- តម្លៃ ១/០,៥០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិត្រពាំងទន្ទឹម ភូមិលាំងជ័យថ្មី ភូមិលាំងជ័យចាស់ ភូមិព្រៃខ្លុង ភូមិត្រពាំងត្រយឹង ភូមិអង្គតាអាំ ភូមិឃ្លៃចាស់ ភូមិឃ្លៃថ្មី ភូមិត្រពាំងសំរោង និងភូមិស្រែគុយ

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៩- ឃុំកាត់ភ្លុក មាន ១១ភូមិ គឺ ÷ ភូមិត្រពាំងពើក ភូមិថ្កុកបី ភូមិព្រៃសំព័រ ភូមិវាលល្វាង ភូមិភ្នំតូច ភូមិយោងទោង ភូមិរកាធំ ភូមិចបក់ ភូមិអូរ ភូមិរកាកោង និងភូមិក្រោលក្របី

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១០- ឃុំទួលសាលា មាន ១៧ភូមិ គឺ ÷ ភូមិធ្លក ភូមិស្រែឃ្លេ ភូមិកោះឈើទាល ភូមិត្រពាំងកក់ ភូមិខ្លាផល់ ភូមិវាល ភូមិទួលសាលា ភូមិតាតួវ ភូមិត្នោត ភូមិចង្រៀក ភូមិអូរ ភូមិស្វាយរំពារ ភូមិដូនពេញ ភូមិតាអាំ ភូមិព្រីង ភូមិរំលើក និងភូមិព្រៃរងោង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១១- ឃុំផុង មាន ១៣ភូមិ គឺ ÷ ភូមិត្រពាំងវែង ភូមិត្រពាំងលាប ភូមិឈូកគៀប ភូមិព្រៃម្នោ ភូមិអន្លង់ជុំ ភូមិសំបួរមាស ភូមិស្រែរលួស ភូមិទួល ភូមិថ្មី ភូមិត្រពាំងទឹកជ្រៅ ភូមិទួលភ្លាស ភូមិបឹងតាមុំ និងភូមិដំបូកខ្ពស់

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១២- ឃុំទួលអំពិល មាន ១៥ភូមិ គឺ ÷ ភូមិត្រពាំងខ្យង ភូមិផាន ភូមិត្រពាំងជំរៅ ភូមិអង្គក្តី ភូមិព្រៃពាយ ភូមិអង្គរនាង ភូមិសង្គ្រាមបូរណ៍ ភូមិតាម៉ឺន ភូមិមីលាវ ភូមិរកាពក ភូមិកែស្រែង ភូមិដំណាក់ព្រាច ភូមិព្រៃខ្លា ភូមិត្រពាំងទន្លាប់ និងភូមិព្រៃស្រឡែង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១៣- ឃុំភក្តី មាន ០៩ភូមិ គឺ ÷ ភូមិកោកកណ្តាល ភូមិសមាគមខាងកើត ភូមិសមាគមខាងលិច ភូមិច្រកព្រាល ភូមិព្រៃវែល ភូមិឈូករដ្ឋ ភូមិព្រៃខ្លា ភូមិតានក និងភូមិអូរតាពូង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១៤- ឃុំភារីមានជ័យ មាន ១៣ភូមិ គឺ ÷ ភូមិព្រះម្លប់ ភូមិថ្មី ភូមិព្រៃកញ្ចាន់ ភូមិព្រៃដោង ភូមិដាសស្គរ ភូមិត្រពាំងផ្ទុង ភូមិពីរ ភូមិតាធម្ម ភូមិព្រៃរោង ភូមិសំរោងពងទឹក ភូមិតាសោមអក ភូមិសាច់ត្រី និងភូមិទឹកថ្លា

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១៥- ឃុំពោធិអង្រ្គង មាន ១៩ភូមិ គឺ ÷ ភូមិត្រពាំងឈូក ភូមិសង្គមមានជ័យ ភូមិកណ្តាល ភូមិពោធិធំ ភូមិពោធិកណ្តាល ភូមិប្រនាងចាស់ ភូមិប្រនាងថ្មី ភូមិព្រៃឥដ្ឋ ភូមិត្រពាំងប្រិយ៍ ភូមិព្រៃខ្លា ភូមិត្រពាំងកក់ ភូមិសេរីជួបជុំ ភូមិត្រកួន ភូមិសេរីភ័ក្ត ភូមិនរាយណ៍ ភូមិព្រៃក្តាភេម ភូមិព្រៃស្រួល ភូមិក្រញូង និងភូមិត្រពាំងគៀត

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ស្រុកថ្លុង

អចលនទ្រព្យទាំងឡាយដែលស្ថិតនៅស្រុកថ្លុង ត្រូវកំណត់តម្លៃសំណង់ និងដី ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម ÷

ក- សំណង់ ÷ *(ឯកតាគិត ÷ ជាដុល្លារ)*

ប្រភេទសំណង់	ដល់ ១០ឆ្នាំ (តម្លៃ/១ម^2)			លើស ១០ឆ្នាំ (តម្លៃ/១ម^2)		
	សំណង់ឥដ្ឋបេតុង	សំណង់មិនមែនឥដ្ឋបេតុង	ខុនដូ	សំណង់ឥដ្ឋបេតុង	សំណង់មិនមែនឥដ្ឋបេតុង	ខុនដូ
ជាន់ក្រោមដី	១៨០	១៨០	១៨០	១៥០	១៥០	១៥០
ជាន់ផ្ទាល់ដី	១៨០	៨០	៥០០	១៧០	៧០	៤០០
ជាន់ទី១	១៦០	៧០	៥០០	១១០	៦០	៤០០
ជាន់ទី២ - ទី៥	១៣០	៦០	៥០០	៨០	៥០	៤០០
ជាន់ទី៦ - ទី១០	៥៥០	៥៥០	៥៥០	៤៥០	៤៥០	៤៥០
ចាប់ពីជាន់ទី១១ ឡើងទៅ	៦៥០	៦៥០	៦៥០	៥៥០	៥៥០	៥៥០

ខ- ដី ÷

ប្រភេទមួយ ÷ តម្លៃ ៥០ដុល្លារ ក្នុង១ម៉ែត្រក្រឡា ÷ ដីស្ថិតនៅផ្សារ

- ក្នុងទីប្រជុំជនផ្សារខ្លោច

ប្រភេទពីរ ÷ តម្លៃ ២០ដុល្លារ ក្នុង១ម៉ែត្រក្រឡា ÷ ដីស្ថិតនៅផ្សារ

- ក្នុងទីប្រជុំជនផ្សារអមលាំង

ប្រភេទបី ÷ តម្លៃ ៣ដុល្លារ ដីលំនៅដ្ឋាន/ តម្លៃ ១ដុល្លារ ដីស្រែ-ចំការ ក្នុង១ម៉ែត្រក្រឡា ÷

- សងខាងកំណាត់ផ្លូវជាតិលេខ៥១ (ទៅកើត) ចាប់ពីសាលាស្រុក ដល់ព្រំប្រទល់ស្រុកឧដុង្គ
- សងខាងកំណាត់ផ្លូវជាតិលេខ៥១ (ទៅលិច) ចាប់ពីសាលាស្រុក ដល់ព្រំប្រទល់ស្រុកនិរ៉ាល់

(លើកលែងកំណាត់ផ្លូវដែលមានចែងក្នុងប្រភេទមួយ និងប្រភេទពីរ)

<u>**ប្រភេទបួន**</u> ÷ ដីក្រៅពីការកំណត់ក្នុងប្រភេទខាងលើ (ដីលំនៅដ្ឋាន/ដីស្រែ-ចំការ)

១- ឃុំអមលាំង មាន ១០ភូមិ គឺ ÷

ក. ភូមិកុមារមាស ភូមិស្នួល ភូមិក្រាំងដូង ភូមិថ្មល់បំបែក ភូមិតាកោង ភូមិថ្មគប់ និងភូមិទំនាប

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិក្រាំងចំបក់ ភូមិអូរអង្គ្រ និងភូមិគោក

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

២- ឃុំភក្តីពង់ មាន ១១ភូមិ គឺ ÷

ក. ភូមិទទឹងថ្ងៃ ភូមិដុំខ្វិត ភូមិអូរក្រសារ និងភូមិទេពភិរម្យ

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិស្យា ភូមិព្រៃមិច ភូមិអំពិលក្លារ ភូមិកន្ទាំ ភូមិរាមកណ្តាល ភូមិតាំងបន្ទាយ និងភូមិបន្ទាយល្វើ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- ឃុំប្រាំបីមុម មាន ១០ភូមិ គឺ ÷

ក. ភូមិអន្លង់ជ្រៃ ភូមិត្រពាំងស្រោក ភូមិត្រាញ់វែង ភូមិត្បែងប្រជាប់ ភូមិចំបក់ធំ ភូមិត្រពាំងគ្រើញ និងភូមិតាំងពោធិ៍

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិឡូ ភូមិព្រៃវែង និងភូមិដូនទិព្វ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៤- ឃុំរងរឿង មាន ០៩ភូមិ គឺ ÷

ក. ភូមិក្រាំងតាចរ ភូមិចំបក់សរ និងភូមិថ្មី

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិរលាំងឡើង ភូមិត្បែង ភូមិអង្គភូមិទឹកលេងទី១ ភូមិទឹកលេងទី២ ភូមិត្រពាំងត្របែក និងភូមិតាមុនី

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំមនោរម្យ មាន ១០ភូមិ គឺ ÷

ក. ភូមិគោល និងភូមិថ្នល់

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិតាមុំ ភូមិទំពារ ភូមិវាលពន់ ភូមិចំបក់ផ្អែម ភូមិតាំងរលាំង ភូមិច្រកខ្ទង ភូមិតាំងស្លុក និងភូមិមនោរម្យ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៦- ឃុំយាអង្គ មាន ១៤ភូមិ គឺ ÷

ក. ភូមិទួលថ្មី ភូមិរំចេក ភូមិព្រៃធំ ភូមិស្វាយ ភូមិថ្មីជជ្រុក ភូមិព្រិចខ្ពស់ និងភូមិក្រវៀក

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិពាណិជ្ជ ភូមិស្បា ភូមិព្រៃទីទុយ ភូមិក្រាំងរំពាក់ ភូមិរលាំងបែង ភូមិត្រោកលាក់ និងភូមិល្មាទេ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៧- ឃុំទំពមាន មាន ០៦ភូមិ គឺ ÷ ភូមិស្វាយព្រៃ ភូមិព្រៃសំរោង ភូមិត្រពាំងជងទឹក ភូមិស្រែអណ្តូង ភូមិស្តៅវស្សា និងភូមិអញ្ញាសេះ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ស្រុកឱរ៉ាល់

អចលនទ្រព្យទាំងឡាយដែលស្ថិតនៅស្រុកឱរ៉ាល់ ត្រូវកំណត់តម្លៃសំណង់ និងដី ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម ៖

ក- សំណង់ ៖ *(ឯកតាគិត ៖ ជាដុល្លារ)*

ប្រភេទសំណង់	ដល់ ១០ឆ្នាំ (តម្លៃ/១ម²)			លើស ១០ឆ្នាំ (តម្លៃ/១ម²)		
	សំណង់ឥដ្ឋបេតុង	សំណង់មិនមែនឥដ្ឋបេតុង	ខុនដូ	សំណង់ឥដ្ឋបេតុង	សំណង់មិនមែនឥដ្ឋបេតុង	ខុនដូ
ជាន់ក្រោមដី	១៨០	១៨០	១៨០	១៥០	១៥០	១៥០
ជាន់ផ្ទាល់ដី	១៨០	៨០	៥០០	១៧០	៧០	៤០០
ជាន់ទី១	១៦០	៧០	៥០០	១១០	៦០	៤០០
ជាន់ទី២ - ទី៥	១៣០	៦០	៥០០	៨០	៥០	៤០០
ជាន់ទី៦ - ទី១០	៥៥០	៥៥០	៥៥០	៤៥០	៤៥០	៤៥០
ចាប់ពីជាន់ទី១១ ឡើងទៅ	៦៥០	៦៥០	៦៥០	៥៥០	៥៥០	៥៥០

ខ- ដី ៖

<u>ប្រភេទមួយ</u> ៖ តម្លៃ ៥០ដុល្លារ ក្នុង១ម៉ែត្រក្រឡា ៖ ដីស្ថិតនៅផ្សារ

- ក្នុងទីប្រជុំជនផ្សារកន្ទួត

<u>ប្រភេទពីរ</u> ៖ តម្លៃ ៣ដុល្លារ ដីលំនៅដ្ឋាន/១ដុល្លារ ដីស្រែ-ចំការ ក្នុង១ម៉ែត្រក្រឡា ៖

- សងខាងកំណាត់ផ្លូវជាតិលេខ៤៤ (ផ្លូវឱរ៉ាល់) ចាប់ពីព្រំប្រទល់ស្រុកសំរោងទង ដល់ព្រំប្រទល់ស្រុកថ្ពង (លើកលែងកំណាត់ផ្លូវដែលមានចែងក្នុងប្រភេទមួយ)

<u>ប្រភេទបី</u> ៖ ដីក្រៅពីការកំណត់ក្នុងប្រភេទខាងលើ (ដីលំនៅដ្ឋាន/ដីស្រែ-ចំការ)

១- ឃុំសង្កែសាទប មាន ១៥ភូមិ គឺ ៖

ក. ភូមិទួលឈើនាង ភូមិត្រពាំងគង ភូមិតាំងស្រីង ភូមិតាម៉ិញ ភូមិស្រែវៀន ភូមិកន្ទួត ភូមិផ្សារកន្ទួត និងភូមិក្រាំងពង្រ

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិជំនាប់ ភូមិតាដែស ភូមិយ៉ាងពិស ភូមិព្រីងកោង ភូមិពាម ភូមិគោក និងភូមិដំបងវិញ

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

២- ឃុំតាសាល មាន ០៨ភូមិ គឺ ៖

ក. ភូមិអន្លង់សង្កែ ភូមិតាសាល និងភូមិកំប៉េះ

- តម្លៃ ០,៨០/០,៤០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ. ភូមិកោះរុន ភូមិក្នុងអាយ ភូមិរោងម៉ាស៊ីន ភូមិត្រពាំងឆ្នា និងភូមិដូង

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- ឃុំរស្មីសាមគ្គី មាន ០៥ភូមិ គឺ ÷ ភូមិព្រៃមាន ភូមិរស្មី ភូមិសាមគ្គី ភូមិអូរផ្តៅ និងភូមិពាមរស់

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៤- ឃុំត្រពាំងជោរ មាន ១៤ភូមិ គឺ ÷ ភូមិព្រៃផ្តៅ ភូមិផ្លូវគោ ភូមិពាមល្វា ភូមិល្ងើម ភូមិច្រទៀក ភូមិរលាក់កងជើង ភូមិឱរ៉ាល់ ភូមិសំរោង១ ភូមិសំរោង២ ភូមិជ្រោវ ភូមិល្វាយទាប ភូមិឈើទាល ភូមិអូរគោង និងភូមិត្រពាំងអង្គ្រង

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំហោងសំណំ មាន ០៩ភូមិ គឺ ÷ ភូមិតាំងរបង ភូមិចំបុី ភូមិក្រាំងពពី ភូមិដីឆ្នាំង ភូមិក្រាំងតាភ័ ភូមិទួលធ្នង់ ភូមិព្រៃទទឹង ភូមិមនោរម្យ និងភូមិក្រាំង

- តម្លៃ ០,៥០/០,២៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៣០/០,១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

តទៅរាជកិច្ចលេខ ៨១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ១៧៧/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៤

ប្រកាស

ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

សម្រេច

ផ្ទះលេខ ០៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧៦ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ ១._

ប្រកាសនេះ មានគោលបំណងកំណត់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដែលបានទឹងកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

ទម្រង់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ប្រការ ២._

ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវកំណត់ដូចខាងក្រោម:

ក.តំបន់ភ្នំពេញ និងតំបន់ជុំវិញ

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌ពងមាន់ មានហោប៉ៅពីរមានគំរប។
- នៅផ្នែកខាងលើនៃហោប៉ៅអាវខាងឆ្វេង ត្រូវមានពាក់ស្លាកឈ្មោះ មានផ្ទៃពណ៌ទឹកក្រូច ដែលមានប្រវែង ១២ សម កំពស់ ៣ សម និងត្រូវបញ្ជាក់អំពីឈ្មោះ និងអត្តលេខរបស់មគ្គុទ្ទេសក៍ខ្លួនផ្ទាល់។ នៅលើដៃអាវខាងឆ្វេង ត្រូវមានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍ ដែលមានរាងមូល ហើយមានអង្កត់ផ្ចិតប្រវែង ៦ សម និងត្រូវមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូបដែលមានទំហំ ៣ សម ស្មើជ្រុង។
- នៅលើដៃអាវខាងស្តាំ ត្រូវមានស្លាកសញ្ញាសម្គាល់តំបន់ក្នុងដែនអាជីវកម្មរបស់មគ្គុទ្ទេសក៍ទេស-ចរណ៍ ដែលមានអង្កត់ផ្ចិត ៦ សម កំពស់ ៤.៥ សម និងផ្ទៃពណ៌ទឹកក្រូច អមជាមួយរូបភាព ដែលបង្ហាញពីលក្ខណៈពិសេសនៃតំបន់ភ្នំពេញ និងតំបន់ជុំវិញ។
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាបុរស។
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេស-ចរណ៍ជានារី ។
- ត្រូវមានស្បែកជើងសមរម្យ (ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

ខ.តំបន់សៀមរាបអង្គរ និងតំបន់ជុំវិញ

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌ពងមាន់ មានហោប៉ៅពីរមានគំរប ។
- នៅផ្នែកខាងលើនៃហោប៉ៅអាវខាងឆ្វេង ត្រូវមានពាក់ស្លាកឈ្មោះ មានផ្ទៃពណ៌បៃតង ដែលមានប្រវែង ១២ សម កំពស់ ៣ សម និងត្រូវបញ្ជាក់អំពីឈ្មោះ និងអត្តលេខរបស់មគ្គុទ្ទេសក៍ខ្លួនផ្ទាល់។ នៅលើដៃអាវខាងឆ្វេង ត្រូវមានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍ ដែលមានរាងមូល ហើយមានអង្កត់ផ្ចិតប្រវែង ៦ សម និងត្រូវមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូបដែលមានទំហំ ៣ សម ស្មើជ្រុង។
- នៅលើដៃអាវខាងស្តាំ ត្រូវមានស្លាកសញ្ញាសម្គាល់តំបន់ក្នុងដែនអាជីវកម្មរបស់មគ្គុទ្ទេសក៍ទេស-ចរណ៍ ដែលមានអង្កត់ផ្ចិត ៦ សម កំពស់ ៤.៥ សម និងផ្ទៃពណ៌បៃតង អមជាមួយរូបភាព ដែលបង្ហាញពីលក្ខណៈ ពិសេសនៃតំបន់សៀមរាបអង្គរ និងតំបន់ជុំវិញ។

- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាបុរស។
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេស-ចរណ៍ជានារី ។
- ត្រូវមានស្បែកជើងសមរម្យ (ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

គ.តំបន់ឆ្នេរ

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌ពងមាន់ មានហោប៉ៅពីរមានគំរប ។
- នៅផ្នែកខាងលើនៃហោប៉ៅអាវខាងឆ្វេង ត្រូវមានពាក់ស្លាកឈ្មោះ មានផ្ទៃពណ៌ផ្ទៃមេឃ ដែលមានប្រវែង ១២ សម កំពស់ ៣ សម និងត្រូវបញ្ជាក់អំពីឈ្មោះ និងអត្តលេខរបស់មគ្គុទ្ទេសក៍ខ្លួនផ្ទាល់។ នៅលើដៃអាវខាងឆ្វេង ត្រូវមានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍ ដែលមានរាងមូល ហើយមានអង្កត់ផ្ចិតប្រវែង ៦ សម និងត្រូវមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូបដែលមានទំហំ ៣ សម ស្មើជ្រុង។
- នៅលើដៃអាវខាងស្តាំ ត្រូវមានស្លាកសញ្ញាសម្គាល់តំបន់ក្នុងដែនអាជីវកម្មរបស់មគ្គុទ្ទេសក៍ទេស-ចរណ៍ ដែលមានអង្កត់ផ្ចិត ៦ សម កំពស់ ៤.៥ សម និងផ្ទៃពណ៌ផ្ទៃមេឃ អមជាមួយរូបភាព ដែលបង្ហាញពីលក្ខណៈពិសេសនៃតំបន់ឆ្នេរ។
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាបុរស។
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេស-ចរណ៍ជានារី ។
- ត្រូវមានស្បែកជើងសមរម្យ (ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

ឃ.តំបន់ភូមិភាគឦសាន

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌ពងមាន់ មានហោប៉ៅពីរមានគំរប ។
- នៅផ្នែកខាងលើនៃហោប៉ៅអាវខាងឆ្វេង ត្រូវមានពាក់ស្លាកឈ្មោះ មានផ្ទៃពណ៌ត្នោត ដែលមានប្រវែង ១២ សម កំពស់ ៣ សម និងត្រូវបញ្ជាក់អំពីឈ្មោះ និងអត្តលេខរបស់មគ្គុទ្ទេសក៍ខ្លួនផ្ទាល់។ នៅលើដៃអាវខាងឆ្វេង ត្រូវមានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍ ដែលមានរាងមូល ហើយមានអង្កត់ផ្ចិតប្រវែង ៦ សម និងត្រូវមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូបដែលមានទំហំ ៣ សម ស្មើជ្រុង។
- នៅលើដៃអាវខាងស្តាំ ត្រូវមានស្លាកសញ្ញាសម្គាល់តំបន់ក្នុងដែនអាជីវកម្មរបស់មគ្គុទ្ទេសក៍ទេស-ចរណ៍ ដែលមានអង្កត់ផ្ចិត ៦ សម កំពស់ ៤.៥ សម និងផ្ទៃពណ៌ត្នោត អមជាមួយរូបភាព ដែលបង្ហាញពីលក្ខណៈ ពិសេសនៃតំបន់ភូមិភាគឦសាន ។
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាបុរស។
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌ខៀវទឹកប៊ិចចាស់ សម្រាប់មគ្គុទ្ទេសក៍ទេស-ចរណ៍ជានារី ។
- ត្រូវមានស្បែកជើងសមរម្យ (ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដែលមានចែងខាងលើ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី៣

ទម្រង់បណ្ណសម្គាល់ខ្លួន និងនាមបណ្ណសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ប្រការ ៣._

បណ្ណសម្គាល់ខ្លួនមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់៖

- មានប្រវែង ៥.៥ សម និងកំពស់ ៩ សម ។
- នៅផ្នែកខាងលើខាងមុខបណ្ណសម្គាល់ មានរូបថតទំហំ ៤ សម គុណនឹង ៦ សម។ មានបញ្ជាក់អំពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត តំបន់ប្រតិបត្តិការអាជីវកម្ម និងភាសារបស់មគ្គុទ្ទេសក៍ទេសចរណ៍នៅពីក្រោមរូបថត ។
- នៅផ្នែកខាងក្រោមខាងមុខបណ្ណសម្គាល់ មានហត្ថលេខា និងត្រាទទួលស្គាល់ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍។
- ផ្នែកខាងលើខាងក្រោយបណ្ណសម្គាល់មានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍។ នៅផ្នែកកណ្តាលបណ្ណសម្គាល់មានសរសេរឃ្លា "**ខ្ញុំជាមគ្គុទ្ទេសក៍ប្រកបដោយវិជ្ជាជីវៈ និងភាពស្មោះត្រង់**" ។
- នៅផ្នែក្រោមខាងក្រោយបណ្ណសម្គាល់មានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុ-ទ្ទេសក៍ទេសចរណ៍គ្រប់រូប ដែលមានទំហំ ៣ សម ស្មើជ្រុង។
- ខ្សែស្លាកសញ្ញាសម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍ មានទំហំ ១.៥ សម ហើយមានសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស នូវតំបន់នៃមគ្គុទ្ទេសក៍ទេសចរណ៍ទៅតាមតំបន់នីមួយៗ ។

បណ្ណសម្គាល់សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានចែងខាងលើជា ឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៤._

នាមបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់៖

- មានប្រវែង ៩សម និងកំពស់ ៥.៥ សម។
- នៅផ្នែកខាងឆ្វេងមុខនាមបណ្ណមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សម្គាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូប ដែលមានទំហំ ៣ សម ស្មើជ្រុង។
- មានបញ្ជាក់អំពីឈ្មោះ លេខកូដ និងភាសារបស់មគ្គុទ្ទេសក៍ទេសចរណ៍ នៅពីក្រោមលេខសម្ងាត់ពិសេស (QR Code) ។
- ផ្នែកខាងក្រោយ មានរូបសញ្ញា និងអក្សរដែលមានអត្ថន័យថា "**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ**" នៅផ្នែកខាងលើចំកណ្តាល រួមនឹងការពិពណ៌នាអំពីគេហទំព័រ លេខទូរស័ព្ទទំនាក់ទំនង អាសយដ្ឋានសារអេឡិចត្រូនិច និងអាសយដ្ឋានស្នាក់នៅរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ។

នាមបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានចែងខាងលើ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី៤

ភារកិច្ចមគ្គុទ្ទេសក៍ទេសចរណ៍ និងវណ្ណកម្ម

ប្រការ ៥._

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន និងស្លាកសញ្ញាសម្គាល់ ដែលបានកំណត់នៅពេលបំពេញការងារនាំភ្ញៀវទេសចរគ្រប់ពេលវេលា។

ប្រការ ៦._

ក្នុងពេលបំពេញការងារ មគ្គុទ្ទេសក៏ទេសចរណ៍រូបណាមិនស្លៀកសំលៀកបំពាក់ឯកសណ្ឋាន និងសញ្ញាសម្គាល់ដែលបានកំណត់ខាងលើ ត្រូវទទួលពិន័យតាមប្រកាសលេខ ១៥៣ ប្រក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់មគ្គុទ្ទេសក៏ទេសចរណ៍ថ្នាក់តំបន់ ។

ជំពូកទី៥

អន្តរប្បញ្ញត្តិ

ប្រការ ៧._

បណ្ណសម្គាល់ និងនាមបណ្ណមគ្គុទ្ទេសក៏ទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ កន្លងមក ដែលមានសុពលភាពត្រូវបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៏ទេសចរណ៍ដែលមានបំណងស្នើសុំបណ្ណសម្គាល់ និងនាមបណ្ណថ្មី ត្រូវអនុវត្តតាមលក្ខខណ្ឌ និងការកំណត់ដូចមានចែងក្នុងប្រកាសនេះ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

ប្រការ ៨._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩._

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ គ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ ប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលអនុវត្តតាមខ្លឹមសារប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ថោង ខុន

កន្លែងទទួលៈ

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងស្ថាប័នពាក់ព័ន្ធ*
- *អគ្គស្នងការនគរបាលជាតិ*
  "ដើម្បីជ្រាបជាព័ត៌មាន"
- *សាលារាជធានី-ខេត្ត*
- *ដូចក្នុងប្រការ ៩*
  "ដើម្បីអនុវត្ត"
- *សមាគមមគ្គុទ្ទេសក៏ទេសចរណ៍*
- *សមាគមទីភ្នាក់ងារទេសចរណ៍*
  "ដើម្បីមុខការ"
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ

ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ប្រកាស លេខ១៧៧ ប្រក ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ២០១៤

១. ឧបសម្ព័ន្ធទី១: ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ក. តំបន់ភ្នំពេញ និងតំបន់ជុំវិញ





ខ.តំបន់សៀមរាបអង្គរ និងតំបន់ជុំវិញ



ប្រុស ស្រី ស្រី ស្រី

គ.តំបន់ឆ្នេរ


Cyan :65
Yellow :10
Logo
W: 6cm
H: 4.5cm
Logo
W: 6cm
H: 5.7cm
H: 12cm
H: 3cm
Cyan :25
Yellow :35
Cyan :65
Yellow :10
Cyan :25
Yellow :35


ប្រុស
ស្រី
ស្រី
ស្រី

ឃ.ភូមិភាគឦសាន


Cyan :45
Yellow :05
Logo
W:6cm
H:4.5cm
Logo
W:6cm
H:5.7cm
H:12cm
H:3cm
Cyan :25
Yellow :35
Cyan :45
Yellow :05
Logo
W:6cm
H:4.5cm
Logo
W:6cm
H:5.7cm
H:12cm
H:3cm
Cyan :25
Yellow :35


ប្រុស
ស្រី
ស្រី
ស្រី

២. ឧបសម្ព័ន្ធទី២: ស្តីពីបណ្ណសម្គាល់ខ្លួនមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ក. តំបន់ភ្នំពេញ និងតំបន់ជុំវិញ



ខ.តំបន់សៀមរាបអង្គរ និងតំបន់ជុំវិញ



គ.តំបន់ឆ្នេរ







ឃ.ភូមិភាគឦសាន







៣. ឧបសម្ព័ន្ធទី៣: ស្តីពីនាមបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible]

ប្រកាស
ស្តីពីការបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១៨៦២/១៤ គ.ស.ព ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្គោលហ្វេម ស្តារ អេនធើប្រាយ (ខេមបូឌា) លីមីធីត ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលហ្វេម ស្តារ អេនធើប្រាយ (ខេមបូឌា) លីមីធីត (GOLDFAME STAR ENTERPRISES (CAMBODIA) LIMITED.) តំណាងដោយ លោក ចាន់ ជីគួង សញ្ជាតិខ្មែរ អាយុ ៥៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៤៨៦៣១៤ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ២ ផ្លូវម៉ៅសេទុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ផ្លាកឈ្មោះរោងចក្រ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ្គោលហ្វេម ស្គារ អេនធើប្រាយ (ខេមបូឌា) លីមីធីត "*

ទីតាំងរោងចក្រ៖ *" តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេម ផាកស៊ីន (ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល) "*

ប្រការ២៖ -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៣៖ -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

ប្រការ៤៖ ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

ប្រការ៥៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

ប្រការ៧៖ -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវទិន្នន័យ របាយការណ៍ និងផែនការផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

ប្រការ៨៖ -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

ប្រការ៩៖ -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណ នៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

ប្រការ១១៖ លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

ប្រការ១២៖ ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណាងអ្វីឡើយ។

ប្រការ១៣៖ -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៤

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០.១.៨ [illegible]

ប្រកាស
ស្តីពីការបង្កើតពេលចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១២ អវ. ធត ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ របស់អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន មេហ្សិន ខេសឺរ (ខេមបូឌា) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤។

សម្រេច

ប្រការ១៖ អនុញ្ញាតឲ្យក្រុមហ៊ុន មេហ្សិន ខេសឺរ (ខេមបូឌា) (MAISON KAYSER (CAMBODIA) Co., Ltd.) តំណាងដោយ លោក ALEXANDRE MATCHERET សញ្ជាតិបារាំង អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 11CF64892 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1B RUE 21 PHNOM PENH CAMBODGE. ធ្វើការបង្កើតឡើងលើមុខសញ្ញា ដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១.នំប៉័ង	១០៧១
២.នំគ្រប់ប្រភេទ	១០៧១

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ផ្លាកឈ្មោះរោងចក្រ៖ *" ឡផលិតនំប៉័ង និងនំគ្រប់ប្រភេទ សេហ្សិន ខេសឺរ (ខេមបូឌា)"*
ទីតាំងរោងចក្រ៖ *" ផ្ទះទំនើបរ៉ឺអនម៉ល លេខ១៣២ (ជាន់ទី៣) មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ "*

ប្រការ២៖ -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៣៖ -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

ប្រការ៤៖ ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

ប្រការ៥៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

ប្រការ៧៖ -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវទិន្នន័យ របាយការណ៍ និងផែនការផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

ប្រការ៨៖ -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

ប្រការ៩៖ -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមម៉ែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណ នៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

ប្រការ១១៖ លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

ប្រការ១២៖ ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

ប្រការ១៣៖ -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

បោះពុម្ពនៅអគ្គនាយកដ្ឋាន
រាជកិច្ច និង សេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី